ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងការវិនិយោគសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួនលើព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅតាមដំណាក់កាលនៃវដ្តគម្រោង ពីគ្រប់ប្រភពហិរញ្ញប្បទាន និងនៅគ្រប់កម្រិតរដ្ឋបាល សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសមធមិសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះ ជាអនុក្រឹត្យគោល មានគោលដៅកំណត់គោលការណ៍ជាសារវន្ត និងប្រព័ន្ធនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន និងនៅគ្រប់កម្រិតរដ្ឋបាល ជាអាទិ៍ដូចខាងក្រោម÷

- គោលការណ៍ និងលក្ខខណ្ឌតម្រូវ សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ
- ដំណាក់កាលរួមនៃវដ្តគម្រោងវិនិយោគសាធារណៈ

- តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង
- ការផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈ ជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ
- នីតិវិធីប្រតិបត្តិការនៃការរៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង
- កាតព្វកិច្ចរបាយការណ៍។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដូចខាងក្រោម÷

- គម្រោងហិរញ្ញប្បទានដោយថវិកាជាតិ
- គម្រោងហិរញ្ញប្បទានក្រៅប្រទេស
- គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន
- គម្រោងវិនិយោគសាធារណៈដោយប្រភពហិរញ្ញប្បទានចម្រុះ
- គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ
- គម្រោងវិនិយោគសាធារណៈដោយសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលដទៃទៀត
- គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម។

**មាត្រា៤.-**

និយមន័យនៃវាក្យស័ព្ទ សម្រាប់ប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដោយសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២

## គោលការណ៍ និងលក្ខខណ្ឌតម្រូវ សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ

**មាត្រា៥.-**

ការជ្រើសរើស និងការធ្វើថវិកានីយកម្មគម្រោងវិនិយោគសាធារណៈ ត្រូវគោរពតាមគោលការណ៍រួម ដូចខាងក្រោម÷

- **គោលការណ៍សនិទានកម្ម÷** គម្រោងត្រូវតែមានភាពចាំបាច់ចំពោះសេដ្ឋកិច្ច សង្គម និងបរិស្ថាន ព្រមទាំងឆ្លើយតបនឹងតម្រូវការអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ផែនការមេតាមវិស័យ ផែនការមេតាមភូមិសាស្ត្រ ផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ

របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត របស់រាជរដ្ឋាភិបាល។

- **គោលការណ៍ផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷** គម្រោងត្រូវតែបង្ហាញអំពីផលចំណេញផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពី «គោលការណ៍ណែនាំស្ដីពីការរៀបចំគម្រោង»។
- **គោលការណ៍ជម្រើសប្រសើរបំផុត÷** គម្រោងត្រូវតែមានឧត្តមភាពប្រៀបធៀប និងផលសេដ្ឋកិច្ចនិងសង្គម ខ្ពស់ជាងគេ ធៀបនឹងជម្រើសគម្រោងដទៃផ្សេងទៀត។
- **គោលការណ៍ភាពអាចទ្រទ្រង់បាននៃថវិកា÷** តម្រូវការថវិកា សម្រាប់ចំណាយវិនិយោគ ប្រតិបត្តិការ និងថែទាំ ត្រូវស្ថិតនៅក្នុងភាពអាចទ្រទ្រង់បាននៃថវិកា និងត្រូវបានធ្វើសមាហរណកម្មចូលក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ក្របខ័ណ្ឌថវិការយៈពេលមធ្យម ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ។
- **គោលការណ៍ភាពអាចអនុវត្តបាន÷** សមាសភាគគម្រោង អភិក្រម យន្តការនិងរចនាសម្ព័ន្ធ ព្រមទាំងសមត្ថភាពស្ថាប័ន ជាដើម សម្រាប់គ្រប់គ្រង និងអនុវត្តគម្រោង ត្រូវឆ្លើយតបនឹងតម្រូវការ និងបរិការណ៍ជាក់ស្ដែងរបស់កម្ពុជា។
- **គោលការណ៍ភាពរួចរាល់សម្រាប់ការចាប់ផ្ដើមអនុវត្តគម្រោង÷** គោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងការអនុវត្តគម្រោង ផែនការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ផែនការគ្រប់គ្រងបរិស្ថាន ផែនការលទ្ធកម្មគម្រោង ព្រមទាំងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ជាដើម ត្រូវរៀបចំឱ្យបានមុនពេលគម្រោងត្រូវបានអនុម័ត។

**មាត្រា៦.-**

បន្ថែមលើគោលការណ៍រួម ដែលបានបញ្ញត្តក្នុងមាត្រា៥ គោលការណ៍អប្បបរមាដោយឡែក ត្រូវបានដាក់ឱ្យអនុវត្ត សម្រាប់ប្រភេទគម្រោងវិនិយោគសាធារណៈមួយចំនួន ដូចខាងក្រោម÷

- គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម÷ ត្រូវបានអនុញ្ញាត សម្រាប់តែគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងត្រូវមានផលសេដ្ឋកិច្ច និងផលចំណេញហិរញ្ញវត្ថុខ្ពស់ តាមបរិការណ៍ជាក់ស្ដែងរបស់កម្ពុជា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមប្រភេទនៃហេដ្ឋារចនាសម្ព័ន្ធ រៀងរាល់ ៥ ឆ្នាំម្ដង។
- គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ÷ ជាគោលការណ៍ ត្រូវអនុវត្តតាមគោលការណ៍រួមនៃការគ្រប់គ្រងការវិនិយោគសាធារណៈ។ ចំពោះករណីពិសេសមួយចំនួន ដែលត្រូវអនុវត្តតាមអភិក្រម "**ប្រគល់សោរដល់ដៃ**" ត្រូវ÷ (១) គោរពតាមគោលការណ៍តម្លៃស្មើគ្នា ទៅនឹងតម្លៃទីផ្សារនៃទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវធ្វើឯកជនភាវូបនីយកម្ម និង



ស

(២) អនុវត្តតាមរយៈយន្តការ "**អគ្គមេបញ្ជាការតែមួយ និងសេនាធិការតែមួយ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

- គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានចម្រុះ÷ ត្រូវមានភាពទន់ភ្លន់ចំពោះការអនុវត្តគោលការណ៍ផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានា និងលើកកម្ពស់ភាពទាក់ទាញទុនវិនិយោគបន្ថែមពីវិស័យឯកជន សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈសរុប ព្រមទាំងឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន ប្រកបដោយបរិយាប័ន្ន។

**មាត្រា៧.-**

សំណើគម្រោងវិនិយោគសាធារណៈ ត្រូវគោរពតាមលក្ខខណ្ឌ ដូចខាងក្រោម÷

- គ្រប់សំណើគម្រោងទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវឯកសារទស្សនាទានគម្រោង និង/ឬ របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃគម្រោង លើកលែងតែប្រភេទគម្រោង ដែលមានទំហំតូច សាមញ្ញ និងងាយអនុវត្ត ឬ គម្រោងជួសជុល និងស្តារឡើងវិញបន្ទាន់ ឬ មានវេទយិតភាពផ្នែកសន្តិសុខ និងសង្គមខ្ពស់។
- ចំពោះសំណើគម្រោង ដែលមានទំហំមធ្យមនិងធំ គម្រោងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុង ឬ ទីប្រជុំជន ត្រូវភ្ជាប់មកជាមួយនូវផែនការនគរូបនីយកម្ម ផែនការមេតាមវិស័យ ផែនការមេតាមភូមិសាស្ត្រ ផែនការរំលោះថ្លៃដើមវិនិយោគ របាយការណ៍វិភាគផលចំណេញសេដ្ឋកិច្ច របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ផែនការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ព្រមទាំងលក្ខខណ្ឌមួយចំនួនផ្សេងទៀត តាមការចាំបាច់។

លក្ខខណ្ឌវិនិច្ឆ័យ សម្រាប់កំណត់ទំហំ និងភាពស្មុគស្មាញនៃគម្រោង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## វដ្តនៃគម្រោងវិនិយោគសាធារណៈ

**មាត្រា៨.-**

វដ្តនៃគម្រោងវិនិយោគសាធារណៈ ត្រូវមាន ៨ ដំណាក់កាល ដូចខាងក្រោម÷

- **ដំណាក់កាលទី១ - ការធ្វើអត្តសញ្ញាណកម្ម និងការរៀបចំសំណើគម្រោងបឋម÷** ក្រសួង ស្ថាប័នជំនាញ ត្រូវកំណត់អត្តសញ្ញាណគម្រោង រៀបចំសំណើគម្រោងបឋម ឬ ឯកសារទស្សនាទានគម្រោងដោយអនុលោមតាមគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយតាម

វិស័យ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ដើម្បីធ្វើអាទិភាវូបនីយកម្មសំណើគម្រោងវិនិយោគ សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការវិនិយោគសាធារណៈ។

- **ដំណាក់កាលទី២ - ការសិក្សាសមិទ្ធិលទ្ធភាព និងការវាយតម្លៃសំណើគម្រោង៖** ក្រសួង ស្ថាប័នជំនាញ ត្រូវសិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃគម្រោងលើទិដ្ឋភាពពាក់ព័ន្ធរួមមាន៖ បច្ចេកទេស តម្លៃ ហានិភ័យ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ច្បាប់ ហេតុប៉ះពាល់បរិស្ថាននិងសង្គម ព្រមទាំងយន្តការនិងសមត្ថភាពស្ថាប័ន សម្រាប់គ្រប់គ្រងនិងតាមដានការអនុវត្តគម្រោង ដោយត្រូវគោរពតាមគោលការណ៍ស្តីពីការសិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃសំណើគម្រោង ដែលមានជាធរមាន។

- **ដំណាក់កាលទី៣ - ការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យផ្ទៀងផ្ទាត់ឡើងវិញលើការវាយតម្លៃសំណើគម្រោងរបស់ក្រសួង ស្ថាប័នជំនាញ។

- **ដំណាក់កាលទី៤ - ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាព ដែលបានឆ្លងកាត់ដំណាក់កាលទី៣ ដើម្បីកំណត់ប្រភពហិរញ្ញប្បទាន និងធ្វើថវិកានីយកម្ម ក្នុងគោលដៅធានាប្រសិទ្ធភាពសេដ្ឋកិច្ច សមធម៌សង្គម និងលទ្ធភាពនៃថវិកា ក្នុងដំណាក់កាលវិនិយោគ ប្រតិបត្តិការ និងថែទាំ។ មានតែគម្រោង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អនុលោមតាមលក្ខណៈវិនិច្ឆ័យ និងវិធានជាធរមានប៉ុណ្ណោះ នឹងត្រូវបានជ្រើសរើសចេញពីបញ្ជីគម្រោងអាទិភាព សម្រាប់ការធ្វើថវិកានីយកម្ម។ តារាងសង្ខេបអំពីបញ្ជីគម្រោងវិនិយោគសាធារណៈ ដែលត្រូវបានជ្រើសរើស សម្រាប់ការធ្វើថវិកានីយកម្ម ត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ។

- **ដំណាក់កាលទី៥ - ការគ្រប់គ្រង និងការអនុវត្តគម្រោង៖** ក្រសួង ស្ថាប័នជាម្ចាស់សំណើគម្រោង សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមអនុវត្តកិច្ចលទ្ធកម្ម រាប់ទាំងការរៀបចំផែនការ ការអនុវត្តនីតិវិធីលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា។ ចំពោះករណីគម្រោងវិនិយោគ ដែលមានទំហំមធ្យម ឬ ធំ ត្រូវរៀបចំក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិកាពហុឆ្នាំ។

- **ដំណាក់កាលទី៦ - ការកែសម្រួលគម្រោង៖** ក្រសួង ស្ថាប័នជំនាញ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតាមដានការអនុវត្តគម្រោង ដោយត្រូវផ្ទៀងផ្ទាត់វឌ្ឍនភាពនៃការអនុវត្តគម្រោង ទៅនឹងផែនការអនុវត្តគម្រោង និងកែសម្រួលគម្រោង តាមការចាំបាច់។

- **ដំណាក់កាលទី៧ - ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមគម្រោង៖** ក្រសួង ស្ថាប័នជំនាញ ត្រូវត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឈានទៅធ្វើសេចក្តីសម្រេចលើការប្រគល់-ទទួល ការដាក់ឱ្យប្រើប្រាស់ និងការចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋតាមនីតិវិធីជាធរមាន។

- **ដំណាក់កាលទី៨- ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង÷** ក្រសួង ស្ថាប័នជំនាញ ត្រូវចាត់ចែងរៀបចំការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង ដោយត្រូវរៀបចំចងក្រងជារបាយការណ៍ស្តីពីលទ្ធផលសម្រេចបាន ទាំងលទ្ធផលសម្រេចបានក្នុងរយៈពេលអនុវត្តគម្រោង និងទាំងលទ្ធផលចុងក្រោយ ព្រមទាំងបញ្ហាប្រឈមនៃការអនុវត្តគម្រោង សម្រាប់ជាបទពិសោធក្នុងការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈក្រោយៗទៀត។

## ជំពូកទី៤

## តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា៩.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាម្ចាស់គម្រោង ត្រូវមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ធ្វើអត្តសញ្ញាណកម្ម និងរៀបចំឯកសារទស្សនាទានគម្រោង
- ធ្វើអាទិភាវូបនីយកម្ម
- ផែនការនីយកម្មការវិនិយោគសាធារណៈ
- រៀបចំឯកសារសំណើគម្រោង ដោយត្រូវភ្ជាប់ជាមួយនូវរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព និងរបាយការណ៍វាយតម្លៃសំណើគម្រោង
- គ្រប់គ្រងការអនុវត្តគម្រោង
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង របាយការណ៍ក្រោយបញ្ចប់ការអនុវត្តគម្រោង និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀត
- ព្រមទាំងបំពេញតួនាទី និងភារកិច្ចពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។

**មាត្រា១០.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ពិនិត្យ និងវាយតម្លៃលើសំណើគម្រោង÷ ត្រូវពិនិត្យលើតម្លៃនិងហានិភ័យគម្រោង ផលចំណេញផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃគម្រោង យន្តការគ្រប់គ្រងនិងអនុវត្តគម្រោង ព្រមទាំងកំណត់នូវវិធានការចាំបាច់នានា ដើម្បីកែតម្រូវ និងគ្រប់គ្រងហានិភ័យគម្រោង
- ជ្រើសរើសគម្រោង និងថវិកានីយកម្ម÷ ត្រូវជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាព ដើម្បីធ្វើថវិកានីយកម្ម ក្នុងគោលដៅធានានូវភាពឆ្លើយតបនឹងតម្រូវការជាអាទិភាព ប្រសិទ្ធភាពសេដ្ឋកិច្ចសមធម៌សង្គម លទ្ធភាពនៃថវិកា ភាពរួចរាល់នៃការចាប់ផ្តើមអនុវត្ត និងភាពដែលអាចអនុវត្តបាន

- តាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង៖ ត្រូវតាមដាន និងត្រួតពិនិត្យលើការគ្រប់គ្រង និងអនុវត្តគម្រោង និងវាយតម្លៃអនុលោមភាពតាមវិធាន គោលការណ៍ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ
- ព្រមទាំងបំពេញតួនាទី និងភារកិច្ចពាក់ព័ន្ធផ្សេងទៀត។

**មាត្រា១១.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មការវិនិយោគសាធារណៈ ដែលជាយន្តការបុរេថវិកានីយកម្មការវិនិយោគសាធារណៈ សម្រាប់បំពេញមុខងារជាទ្វារបាលនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ គណៈកម្មការនេះ ត្រូវបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## នីតិវិធីប្រតិបត្តិការនៃការរៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ

**មាត្រា១២.-**

នីតិវិធីប្រតិបត្តិការនៃការរៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ តាមប្រភពហិរញ្ញប្បទាន និងតាមកម្រិតរដ្ឋបាល ត្រូវកំណត់ដោយអនុក្រឹត្យ ឬ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## ភារកិច្ចរបាយការណ៍

**មាត្រា១៣.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាម្ចាស់គម្រោង ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង របាយការណ៍ក្រោយបញ្ចប់ការអនុវត្តគម្រោង និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀត ព្រមទាំងត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានក្នុងការកត់ត្រាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមនៃគម្រោងវិនិយោគសាធារណៈ ក្នុងគោលដៅពង្រឹងតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃការវិភាជ និងប្រើប្រាស់ធនធានសាធារណៈ។

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាម្ចាស់គម្រោង ត្រូវចែករំលែកជាមួយក្រសួងផែនការនូវរបាយការណ៍វឌ្ឍនភាពធៀបនឹងគោលដៅនៃការអនុវត្តគម្រោង និងរបាយការណ៍ក្រោយបញ្ចប់ការអនុវត្តគម្រោង ដើម្បីតាមដាន និងបូកសរុបវឌ្ឍនភាពការងារនៃការអនុវត្តគម្រោងវិនិយោគសាធារណៈ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីនៃគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានសហគ្រាសសាធារណៈ ប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាល និងប្រធានគ្រប់អង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៧ុ៥ ២ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ខែ មីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# សទ្ទានុក្រម

**ការកែសម្រួលគម្រោង**

សំដៅដល់ដំណើរការនៃការកែសម្រួលផ្នែកណាមួយនៃគម្រោង ដែលបានអនុម័តរួចហើយ ជាអាទិ៍÷ ការកែសម្រួលតម្លៃ វិសាលភាព សកម្មភាព ឬ រយៈពេលនៃការអនុវត្តគម្រោងជាដើម។

**ការវាយតម្លៃសំណើគម្រោង**

សំដៅដល់ដំណើរការវាយតម្លៃលើទិដ្ឋភាពសំខាន់ៗនៃសំណើគម្រោង ជាអាទិ៍÷ បច្ចេកទេស តម្លៃ ហានិភ័យ ផលសេដ្ឋកិច្ចនិងសង្គម ហេតុប៉ះពាល់បរិស្ថាននិងសង្គម និងថវិកាជាដើម។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម**

សំដៅដល់ការសិក្សាលើធនធានបរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម រួមទាំងតម្រូវការក្នុងការធ្វើលទ្ធកម្មដី និងការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ដោយភាគច្រើនពឹងផ្អែកទៅលើទិន្នន័យមានស្រាប់ដែលមាននៅក្នុងនិងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករ និងវិភាគនូវសក្ដានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតមានឡើងដោយសារសកម្មភាពរបស់គម្រោង សំដៅរកវិធានការបញ្ចៀស ឬ កាត់បន្ថយនូវហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានឱ្យដល់កម្រិតអតិបរមា។

**ការសិក្សាសមិទ្ធិលទ្ធភាព**

សំដៅដល់ការសិក្សាស៊ីជម្រៅលើសំណើគម្រោង ដោយរួមបញ្ចូលការវិភាគលើទិដ្ឋភាពពាក់ព័ន្ធ រួមមាន÷ បច្ចេកទេស តម្លៃ ហានិភ័យ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ច្បាប់ ហេតុប៉ះពាល់បរិស្ថាននិងសង្គម ភាពអាចទ្រទ្រង់បាននៃថវិកា ព្រមទាំងយន្តការនិងសមត្ថភាពស្ថាប័ន សម្រាប់គ្រប់គ្រងនិងតាមដានការអនុវត្តគម្រោង ដោយត្រូវគោរពតាមគោលការណ៍ណែនាំលម្អិត និងនីតិវិធីរៀបចំ និងគ្រប់គ្រងប្រតិបត្តិការជាធរមាន។

**កិច្ចសន្យាប្រគល់សោរដល់ដៃ**

សំដៅដល់កិច្ចសន្យា ដែលសម្បទានិកទទួលបានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ តាមរយៈការធ្វើឯកជនភាវូបនីយកម្ម ដើម្បីទទួលខុសត្រូវចាត់ចែង រៀបចំ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឱ្យបានរួចរាល់ សម្រាប់ប្រតិបត្តិការ មុននឹងប្រគល់ជូនភាគីរាជរដ្ឋាភិបាល។

**ទីប្រឹក្សាបច្ចេកទេស** 

## ទ្វារបាលកិច្ច

សំដៅដល់មុខងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង ការធ្វើអាទិភាវូបនីយកម្ម ការជ្រើសរើស និងថវិកានីយកម្ម ព្រមទាំងការតាមដាននិងត្រួតពិនិត្យលើការអនុវត្តគម្រោង។

## ភាពជាដៃគូរវាងរដ្ឋនិងឯកជន

សំដៅដល់ការព្រមព្រៀងគ្នារវាងភាគីរដ្ឋ និងដៃគូឯកជនមួយ ឬ ច្រើន ដើម្បីស្ថាបនា សាងសង់ ជួសជុល គ្រប់គ្រងប្រតិបត្តិការ និង/ឬ ថែទាំលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ទ្រព្យសម្បត្តិគម្រោង ឬ ដើម្បីផ្តល់សេវាសាធារណៈ នៅក្នុងអំឡុងពេលកំណត់ណាមួយ ដោយដៃគូឯកជនត្រូវធ្វើការវិនិយោគ ទទួលបន្ទុកហានិភ័យ និងទទួលអត្ថប្រយោជន៍ដោយផ្អែកលើសមិទ្ធកម្ម និងដោយអនុលោមតាម ខ និងលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន។

## ឯកសារទស្សនាទានគម្រោង

សំដៅដល់ឯកសារទស្សនាទានបឋម ដែលបញ្ជាក់អំពីសនិទានកម្ម គោលដៅនៃគម្រោង តម្រូវការនិងអាទិភាពនៃគម្រោង ការផ្សារភ្ជាប់ទៅនឹងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយតាមវិស័យ។